ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែឧទ្យានជាតិវើនសៃ-សៀមប៉ាង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតឧទ្យានជាតិ វីរៈជ័យ-សៀមប៉ាង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែឧទ្យានជាតិវីរៈជ័យ-សៀមប៉ាង ពីផ្ទៃដីទំហំ៥៧ ៤៦៩(ប្រាំម៉ឺនប្រាំពីរពាន់បួនរយហុកសិបប្រាំបួន)ហិកតា មកផ្ទៃដីទំហំ២៨០ ៣៥៩(ពីរសែនប្រាំបីម៉ឺនបីរយហាសិបប្រាំបួន)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តរតនគិរីនិងខេត្តស្ទឹងត្រែង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីឧទ្យានជាតិវីរៈជ័យ-សៀមប៉ាងខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ៥៧ ៤៦៩(ប្រាំម៉ឺនប្រាំពីរពាន់បួនរយហុកសិបប្រាំបួន)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់ឧទ្យានជាតិវីរៈជ័យ-សៀមប៉ាង និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឦសាន ដែលមានផ្ទៃដីទំហំ២២២ ៨៩០(ពីរសែនពីរម៉ឺនពីរពាន់ប្រាំបីរយកៅសិប)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា ការពារសោភណភាពធម្មជាតិ និងទេសភាព ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ សម្រាប់វិទ្យាសាស្ត្រ ការអប់រំ ការសិក្សាស្រាវជ្រាវ និងការកម្សាន្ត
- លើកកម្ពស់តួនាទី សក្តានុពល និងកិត្យានុភាពនៃប្រព័ន្ធអេកូឡូស៊ី ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- ក្សោលនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ឧទ្យានជាតិវីរៈជ័យ-សៀមប៉ាង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តរតនគិរី និងរដ្ឋបាលខេត្តស្ទឹងត្រែង ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតតំបន់ឧទ្យានជាតិវីរៈសៃ-សៀមប៉ាង អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តរតនគិរី និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣**

**ផែនទីឧទ្យានជាតិវើនសៃ_សៀមប៉ាង ស្ថិតក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី**







**សញ្ញាសម្គាល់**

- ចំណុចនិយាមកា
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:300,000

0 5 10 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**ឧទ្យានជាតិវើនសៃ_សៀមប៉ាង**

មានផ្ទៃដីទំហំ ២៨០ ៣៥៥ហិកតា

**ប្រភពទិន្នន័យ**

| | |
|---|---|
| ខ្សែព្រំប្រទល់តំបន់ការពារធម្មជាតិ | : ក្រសួងបរិស្ថាន |
| ព្រំប្រទល់រដ្ឋបាល | : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០២១) |
| រូបភាព | : Google Earth |
| ផលិតដោយ | : នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃក្រសួងបរិស្ថាន |

## ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

## ចំណុចនិយាមកានៃផែនទីឧទ្យានជាតិវើនសៃ-សៀមប៉ាង

| ID | X | Y |
|---|---|---|
| 1 | 693002 | 1519945 |
| 2 | 695437 | 1519929 |
| 3 | 697192 | 1518285 |
| 4 | 697338 | 1514942 |
| 5 | 698457 | 1513138 |
| 6 | 694235 | 1513637 |
| 7 | 693148 | 1515229 |
| 8 | 694494 | 1516343 |
| 9 | 687630 | 1526598 |
| 10 | 689214 | 1527249 |
| 11 | 690541 | 1525264 |
| 12 | 688700 | 1525419 |
| 13 | 690664 | 1531721 |
| 14 | 691273 | 1530046 |
| 15 | 690148 | 1529225 |
| 16 | 698654 | 1553861 |
| 17 | 696682 | 1552915 |
| 18 | 694149 | 1552386 |
| 19 | 690921 | 1551771 |
| 20 | 692604 | 1549456 |
| 21 | 690424 | 1548684 |
| 22 | 688792 | 1547434 |
| 23 | 689554 | 1545664 |
| 24 | 687536 | 1544731 |
| 25 | 687455 | 1541898 |
| 26 | 687703 | 1539344 |
| 27 | 688327 | 1537981 |
| 28 | 689361 | 1535360 |
| 29 | 688241 | 1531919 |
| 30 | 686098 | 1530766 |
| 31 | 683243 | 1532086 |
| 32 | 679755 | 1532827 |
| 33 | 679901 | 1529258 |
| 34 | 678863 | 1528242 |
| 35 | 678594 | 1526787 |
| 36 | 679284 | 1523924 |
| 37 | 676519 | 1524466 |
| 38 | 674424 | 1522669 |
| 39 | 674919 | 1519487 |
| 40 | 672907 | 1516821 |
| 41 | 668817 | 1516320 |
| 42 | 667210 | 1518027 |
| 43 | 664321 | 1517339 |
| 44 | 661079 | 1517077 |
| 45 | 660881 | 1514855 |
| 46 | 658460 | 1514763 |
| 47 | 658895 | 1511319 |
| 48 | 655598 | 1511319 |
| 49 | 655605 | 1508315 |
| 50 | 653499 | 1506679 |
| 51 | 652195 | 1510656 |
| 52 | 646689 | 1510608 |
| 53 | 640180 | 1509234 |
| 54 | 640913 | 1504264 |
| 55 | 638449 | 1502561 |
| 56 | 638892 | 1500160 |
| 57 | 635215 | 1500609 |
| 58 | 631850 | 1500904 |
| 59 | 628708 | 1500829 |
| 60 | 625414 | 1499991 |
| 61 | 621655 | 1498857 |
| 62 | 621009 | 1503434 |
| 63 | 619229 | 1506048 |
| 64 | 621947 | 1507613 |
| 65 | 623043 | 1510590 |
| 66 | 625432 | 1512320 |
| 67 | 626059 | 1516503 |
| 68 | 627932 | 1519281 |
| 69 | 630615 | 1520051 |
| 70 | 633830 | 1522099 |
| 71 | 635806 | 1524496 |
| 72 | 633917 | 1527107 |
| 73 | 636370 | 1528608 |
| 74 | 636949 | 1532219 |
| 75 | 639473 | 1535453 |
| 76 | 638940 | 1539485 |
| 77 | 641527 | 1541778 |
| 78 | 640405 | 1546463 |
| 79 | 644808 | 1549902 |
| 80 | 647953 | 1553893 |
| 81 | 651057 | 1555504 |
| 82 | 656575 | 1555368 |
| 83 | 655829 | 1557402 |
| 84 | 657069 | 1558001 |
| 85 | 659545 | 1557016 |
| 86 | 658549 | 1558291 |
| 87 | 658180 | 1560341 |
| 88 | 655496 | 1561622 |
| 89 | 653382 | 1560597 |
| 90 | 651429 | 1562218 |
| 91 | 653583 | 1563508 |
| 92 | 653922 | 1566366 |
| 93 | 652793 | 1568913 |
| 94 | 653876 | 1569291 |
| 95 | 655403 | 1568712 |
| 96 | 655940 | 1567903 |
| 97 | 657579 | 1568557 |
| 98 | 658976 | 1570554 |
| 99 | 660424 | 1571054 |
| 100 | 662180 | 1573292 |
| 101 | 663566 | 1574773 |
| 102 | 665347 | 1573766 |
| 103 | 673191 | 1573917 |
| 104 | 672797 | 1572864 |
| 105 | 673551 | 1570762 |
| 106 | 678721 | 1570763 |
| 107 | 684420 | 1570764 |
| 108 | 689722 | 1570821 |
| 109 | 696102 | 1570816 |
| 110 | 696589 | 1568072 |
| 111 | 697068 | 1564916 |
| 112 | 698771 | 1560543 |
| 113 | 699810 | 1557132 |